

# បណ្តាំក្រមង៉ុយ

និពន្ធដោយ ព្រះភិរម្យភាសា អ៊ូ ហៅ ង៉ុយ ជាបទព្រហ្មគីតិ

www.elibraryofcambodia.org

# បណ្ដាំក្រមង៉ុយ

1. នេះបទព្រហ្មប្រាជ្ញប្រែ ប្រាយប្រាប់ខ្មែរទាំងប្រុសស្រី
   ឱ្យប្រិតប្រុងស្មារតី គួរគប្បីឱ្យនស្សាហ៍ ។
2. កុំខ្ជិលកុំល្ងង់ពេក ខំរៀនលេខរៀនអក្ខរា
   រៀនគ្រប់សព្វធម៌អាថ៌ ប្រាជ្ញាផ្សំនឹងគំនិត ។
3. កំណើតកើតជាមនុស្ស មើលឲ្យឆ្លុះទោះឆ្ងាយជិត
   ចេះស្ទាត់ប្រាកដពិត គិតការអ្វីបានគ្រប់យ៉ាង ។
4. មនុស្សល្ងង់មិនផ្ដើលភ្ញាក់ ដូចភ្នែកខ្វាក់ទាំងសងខាង
   អាងរូបគ្មានអ្វីអាង សាងទាបថោកកើតមកខ្លៅ ។
5. ពូជមនុស្សទោះខ្ពស់ទាប កាត់តាមភាពត្រកូលផៅ
   អាក្រក់ល្អសខ្មៅ កាត់កូនចៅដូចដូនតា ។
6. ពូជល្ងង់មិនបានបួស ទុកជាទោសនឹងសាសនា
   អ្នកបួសចេះធម៌អាថ៌ កូនសិក្សាខំរៀនសូត្រ ។
7. ពូជខ្លៅមិនសូវប្រាជ្ញ ពូជកោងកាចមិនសូវស្លូត
   ពូជត្រង់ៗរហូត ពូជភរភូតមិនផុតផៅ ។
8. ឪពុកម្ដាយស្លូតត្រង់ ចិត្តមិនចង់ឱ្យកូនខ្លៅ
   ផេរវាយស្ដីប្រដៅ ឱ្យកូនចៅបានចេះដឹង ។
9. ឪពុកគ្មានតំរិះ ឃើញកូនចេះមិនដែលខឹង
   ឃើញកូនខំប្រិតប្រឹង ឪពុកដឹងតែងត្រេកអរ ។
10. ដាស់តឿនក្រើនរំលឹក ជេរល្ងាចព្រឹកខ្លាចកូនក្រ
    ចង់ឱ្យតែកូនល្អ លោមអង្វរឱ្យកូនខំ ។
11. កូនកាចបំពេញទុក្ខ ម្ដាយឪពុកមានបារម្ភ
    កូនស្លូតដឹងគួរសម មេបាថ្កុំថ្កើនកេរ្តិ៍ឈ្មោះ ។



www.elibraryofcambodia.org

12.ឪពុកម្ដាយខ្សត់ខ្សោយ　　កុំបណ្ដោយឱ្យអាប់យស
ខំរៀនឱ្យបានខ្ពស់　　គ្រាន់សង្គ្រោះដល់មេបា ។
13.អ្នកល្ងង់ហេតុពីខ្ជិល　　ឥតមន្ទិលរៀងធម៌អាថ៌
គួរកូនចៅសិក្សា　　រៀនអក្ខរាទាំងប្រុសស្រី ។
14.កាលអង្គព្រះសាស្ដា　　មានថេរាមានថេរី
ភិក្ខុភិក្ខុនី　　ធម៌បាលីចេះចាំស្ទាត់ ។
15.លោកសង្ឃខ្លះចេះស្ទើរ　　ចេះភ្លើៗធ្វើឱ្យភ្លាត់
ព្រះអង្គទ្រង់សន្មត　　សិក្ខាបទដល់ឥឡូវ ។
16.ទំលាប់ទំនៀមខ្មែរ　　ខំធ្វើស្រែចង់បានស្រូវ
អ្នករៀនច្បាប់ខុសត្រូវ　　ទុកជាផ្លូវបំភ្លឺប្រាជ្ញា ។
17.ស្រុកសៀមលាវបារាំង　　ចេះតតាំងពីដូនតា
ចេះលេខចេះអក្ខរា　　សរសេរទាំងប្រុសស្រី ។
18.ជាតិខ្មែរមិនចេះខ្មាស់　　នាំពីចាស់គំនិតខ្លី
ល្ងង់ដប់ចេះពីរបី　　ចេះជួញក្ដីមិនចេះច្បាប់ ។
19.មិនចេះលេខអក្សរ　　មុខមាត់ល្អប្រាជ្ញាអាប់
ឈ្មោះខ្លួនភ្នែកខ្លួនស្រាប់　　គេសួតប្រាប់ទើបបានដឹង ។

20.ភ្នែកជាភ្លឺក្រឡៃត　　ល្ងង់ព្រោះហេតុមិនខំប្រឹង
កើតទាស់មានចិត្តខឹង　　ពឹងរកគេសរសេរឱ្យ ។
21.មនុស្សក្រហេតុពីខ្ជិល　　មិនរមិលមើលមុខក្រោយ
ម្យ៉ាងខ្សត់ពីព្រោះខ្សោយ　　ញីកខាងឱ្យរង្វើលរក ។
22.ម្យ៉ាងក្រពើព្រោះល្ងង់　　ជួញលិចលង់មិនលៃលក
ទិញថ្លៃទៅលក់ថោក　　ចេះតែយកមិនគិតយល់ ។
23.អ្នកមានៗគំនិត　　ដេកដើរគិតកើតរវល់
ប្រាជ្ញាជាឫសគល់　　កើតអំពល់អំពីទ្រព្យ ។
24.អ្នកល្ងង់នឹងអ្នកចេះ　　បើនឹងរិះរាយរៀបរាប់



www.elibraryofcambodia.org

អ្នកចេះប្រសើរគាប់ លង្ងង់ឥតភ័ព្វអាប់រាសី ។
25. មានរូបមានជីវិត មិនចេះគិតចង់ដឹងអ្វី
រូបប្រុសឬកដូចស្រី នឹងហ៊ានស្ដីគ្មានគេស្ដាប់ ។
26. លង្ងង់ម្យ៉ាងមានអំណាច លង្ងង់កោងកាចអួតចាក់កាប់
ឆាប់ខឹងមិនដឹងច្បាប់ កាលណាស្លាប់គេត្រេកអរ ។
27. អ្នកចេះតំរិះដល់ អ្នកល្ងង់ឆ្ងល់មិនសល់ក្រ
ចេះល្អិតចិត្តជាល្អ ស្វយអាករចូលមិនខ្វះ ។
28. ចេះម្យ៉ាងមានអំណាច អ្នកខ្លៅខ្លាចឱនសំពះ
គេខុសជេរជៀលត្មះ អ្នកខ្លៅខ្លះគេលបខឹង ។
29. ប្រាជ្ញម្យ៉ាងចេះសព្វសុស ប្រព្រឹត្តខុសនោះមិនដឹង
មិនគិតពិនិត្យថ្លឹង ប្រាជ្ញប្រិតប្រឹងប្រដៅគេ ។
30. កូនចៅទោះធំតូច ខុសខិលខូចខឹងវាយជេរ
មារយាទខ្លួនខុសគេ មិនគ្មាន់គ្មេរកិរិយាឯង ។
31. កូនចៅទាំងស្រីប្រុស ការត្រូវខុសគួរគិតក្រែង
គិតគ្រប់សព្វកន្លែង តែងនឹងមានរាល់រូបកាយ ។
32. ភ្នែកបើកភ្លឺមែនពិត មើលឃើញជិតៗវៀងអាយ
ភ្នែកធ្មេចមើលឃើញឆ្ងាយ សព្វសុសសាយមិនសេសសល់ ។
33. រៀនរកស៊ីលក់ទិញ ខាតចំណេញគិតឱ្យដល់
ឱ្យដឹងការកិច្ចកល ទើបកើតផលប្រយោជន៍ខ្លួន ។
34. ឱ្យរៀនលេខនព្វន្ត បូកហាគុណាឱ្យម៉ាំមួន
ដឹសនឹងក្ដារឆ្នួន ក្រែងចិនយួនបំបាត់បាន ។
35. ជញ្ជីងភ្នែកមានល្បាក់ មើលឱ្យជាក់កុំប្រមាណ
ក្រែងខុសខាតមិនខាន ធ្លាប់រាប់អានកុំទុកចិត្ត ។
36. ភ្នែកមនុស្សធំរលីង ភ្នែកជញ្ជីញគេចុចល្អិត
អ្នកល្អថ្លឹងប្រឹងប្រិត ព្រោះអាណិតខ្មែរល្ងង់ខ្លៅ ។



www.elibraryofcambodia.org

37. ចិនមានពីដូរលក់　　　　ស្រូវកន្ទក់កន្ដាំងតៅ
របស់ទោះឆ្អិនឆៅ　　　　សំពត់អាវខោខ្មៅស　　ៗ
38. ខ្មែរអាងស្រូវក្នុងដោក　　　　ដូរថ្លៃថោកអាក្រក់ល្អ
អស់ស្រូវទៅជាក្រ　　　　អង្ករចិនជឿស្រូវឯង　　ៗ
39. ធ្វើស្រែនឿយហត់ណាស់　　　　ចិននៅផ្ទះដេកចំខែង
ផ្ទះចិនពីរបីល្វែង　　　　មានកន្លែងជង្រុកស្រូវ　　ៗ
40. ជាតិខ្មែរឥតគំនិត　　　　ស៊ីមិនចេះគិតមើលខុសត្រូវ
ជឿចិនរាល់រដូវ　　　　កេរ្តិ៍ម៉ែឪចិនអូសអស់　　ៗ
41. ចិនមកពីស្រុកនាយ　　　　មានសំពាយជារបស់
មិនទាន់ចេះខ្មែរសោះ　　　　គ្មានកេរ្តិ៍កោះស្រែចំការ　　ៗ
42. កវែកចង្រ្កានផ្នាំង　　　　ផ្សំកំលាំងនឹងប្រាជ្ញា
អង្រែកជិះលើស្មា　　　　មានម្លូស្លាជាដើមទុន　　ៗ
43. ទំនិញមានគ្រប់មុខ　　　　ផ្លាស់ផ្ទេរទុកដាក់ដោយធុន
ចិនវែកមិនដែលពុន　　　　ស្រូវពោរជន់ពេញជង្រុក　　ៗ
44. ឈប់វែកដេកអង្គុយ　　　　រាប់កាក់លុយប្រមូលទុក
ឪទិនស្រាពីមុខ　　　　ទុកជាផ្នាក់ទាក់កខ្មែរ　　ៗ
45. ចិនច្រើនខ្មាំងចិត្តខ្លៅ　　　　កន្តាំងតៅធ្វើជាស្រែ
គ្មានត្បាល់គ្មានអង្រែ　　　　អង្ករខ្មែរចូលបារចិន　　ៗ
46. ជាតិខ្មែរច្រើនឥតខ្មាស　　　　ស្រេកស្រាណាស់ផឹកជឿសិន
គំនិតគិតមិនឆ្អិន　　　　ផឹកបង្ហិនតែទ្រព្យឯង　　ៗ
47. កំណើតអ្នកផឹកស្រា　　　　បែកប្រាជ្ញាច្រើនកន្លែង
អ្នកម្យ៉ាងបែកខាងល្បែង　　　　មិនគិតក្រែងខ្លាចខ្លួនក្រ　　ៗ
48. អាម្យ៉ាងបែកល្ងចផក់　　　　មារយាទអាក្រក់មិនបានល្អ
ផឹកចោលការរបរ　　　　ចិនទាក់កធ្វើខ្ញុំបាន　　ៗ
49. មិនដឹងខ្លួនជាឆ្កួត　　　　និយាយអួតប្រាប់សន្តាន



www.elibraryofcambodia.org

ថាចិនធ្លាប់រាប់អាន ផឹកថ្មើម៉ានចិនមិនគិត ។
50. ថាចិនមិនចេះកាញ់ ប្រាប់សំឡាញ់ពួកម៉ាកមិត្ត
គួកនទោះឆ្ងាយជិត រឹតប្រមូលលុយឱ្យចិន ។
51. ត្រូវស្រោចង់ស៊ីឆ្ងាញ់ ធុំឆាខ្លាញ់បក់ឆ្វលក្លិន
ឃើញបាយសំម្លឆ្អិន ផ្តាច់ចិត្តចិនយកបាយស៊ី ។
52. ផឹកទឹកបោយត្រឡោក មារយាទទាបថោកឬកសៀធី
ចិនប្រើសែងវែកឈើ ស៊ីញយៗចិនមើលងាយ ។
53. ជាតិចិនកំណាញ់ស្វិត នឹកក្នុងចិត្តមិននិយាយ
មារយាទខ្មែរច្រើនវាយមាយ រលាយទ្រព្យអាភ័ព្វខ្លួន ។
54. ស៊ីឆ្ងាញ់ឆ្អែតស្កប់ស្កល់ ទាបថោកដល់ប្រពន្ធកូន
អាប់យកទាំងបងប្អូន ដល់តាដូនពូជពង្សខ្មែរ ។
55. ជាតិចិនសុទ្ធសឹងស មានទ័លក្រខ្សត់ខ្លះដែរ
ស៊ីផឹកសុទ្ធមានសៃ តមបាយខ្មែរមិនស៊ីសោះ ។
56. មានផ្ទះមានដំណាំ កាប់ដីដាំដោយកៀនកោះ
ដំឡូងត្រាវចេកម្នាស់ ស៊ីមិនអស់ទុកលក់ដូរ ។
57. ខ្មែរច្រើនខ្ជិលប្រមឹក កែងកោងឬកអួតអំបូរ
ខ្វះលុយអង្គុយថ្ងូរ កើបបង្ហូរស្រូវជង្រុក ។
58. កូនអើយរៀងដំណាំ គួរតែដាំឱ្យគ្រប់មុខ
ដីកេរ្តិ៍ម្តាយឪពុក មិនត្រូវទុកចោលទំនេរ ។
59. រាជការវាស់មានថ្លៃ ផ្ចិតមេដៃផ្តាច់ជាកេរ្តិ៍
មិនវាស់លេងទទេរ រើះយកពន្ធរាល់ឆ្នាំ ។
60. ដូងស្វាយអំពៅចេក កុំខ្ជិលពេកដេកប្រចាំ
ម្លូស្លាម្រេចខ្ទឹមថ្នាំ ត្រូវតែដាំកុំឱ្យខ្វះ ។
61. ទេសឯកសំពត់ស ជីវាលល្អដាំកបាស
កុំខ្ជិលតាមចាស់ៗ មនុស្សនៀយណាស់មិនដែលក្រ។



www.elibraryofcambodia.org

62. បន្លែដាំគ្រប់មុខ　　　　យកគ្រាប់ទុកដាំបន្ត
ចាក់ជីជាតិល្អៗ　　　　បង្ហូរស្លពេលល្ងាចព្រឹក ។

63. ម្លូស្លាថ្នាំខ្ទឹមម្រេច　　　　ល្វតលាស់លេចពេលស្រោចទឹក
បានផលផ្លែឬស្លឹក　　　　កុំផ្អើងឬកវាក្រខ្លួន ។

64. ត្រីងៀតផ្អកប្រហុក　　　　ខ្មែរគ្រប់ស្រុកទិញដូរយួន
អំបិលធ្វបក្រមួន　　　　ពីតាដូនតែងដូរទិញ ។

65. ដូរទុកដាក់ដំកល់　　　　ស៊ីឱ្យដល់ខួបខែវិញ
ឱ្យបរិបូណ៌ពោរពេញ　　　　ខាតចំណោញកុំទិញតិច ។

66. អំបិលទិញមួយចុង　　　　ច្រកពេញអុងអាងខាងលិច
កុំទិញក្តោបខ្ទប់វេច　　　　អស់រំពេចគេចទិញទៀត ។

67. អំបិលមួយស្រូវបី　　　　វាល់នឹងល្អីទូលកណ្តៀត
ខ្លួនក្រត្រដរឆ្លៀត　　　　មារយាទយ៉ាងហ្នឹងកុំប្រព្រឹត្ត ។

68. កូនចៅទាំប្រុសស្រី　　　　គួរគប្បីបប្រុងគំនិត
ចិញ្ចឹមជន្មជីវិត　　　　គិតឱ្យវែងកុំគិតខ្លី ។

69. ទំនេរល្ហែធ្វើការ　　　　សូត្រធម៌អាចិទាំងប្រុសស្រី
ឱ្យត្រឹមត្រូវបាលី　　　　ដូចស្រដីខាងដើមស្រាប់ ។

70. រាល់រូបទាំងប្រុសស្រី　　　　កាលចេះស្តីព្រោះចេះស្តាប់
ម៉ែឪតម្រូវប្រាប់　　　　កូនចៅគ្រាប់តាមដូនតា ។

71. ចាស់ម្យ៉ាងសាងសីលទាន　　　　មិនបំពានខុសពុទ្ធដីកា
កូនកាត់តាមមេបា　　　　មិនទៅណាឆ្ងាយពីផ្លូវ ។

72. ចាស់ម្យ៉ាងសាងផលកម្ម　　　　ស្អប់សីលប្រាំដូចសត្រូវ
កូនកាត់តាមមេបា　　　　អាស្រូវភាសវិនាសខ្លួន ។

73. មិនជឿមគ្គជឿផល　　　　ធ្លាក់ទៅដល់អបាយបួន
កងកាំចាំគុំគួន　　　　គេចវេះពួនមិនកំបាំង ។

74. ព្រះអង្គមានពុទ្ធដីកា　　　　ប្រៀបឧបមាជាទីតាំង



www.elibraryofcambodia.org

ដូចគោមានកំលាំង សំរាំងទុកទីមរទេះ ។
75. នឹងបរផ្លូវរៀបត្រង់ ឬនឹងចង់បរគេចវេះ
កង់វិលមិនរបេះ ជិះជើងគោមិនឃ្លាតឃ្លា ។
76. រាល់រូបទាំងតូចធំ ចូលរូងភ្នំ រូងគុហា
យកថ្មផ្ទាំងរាំងទ្វារ កម្មវេរាគោងតាមបាន ។
77. កងសីលមានអង្គប្រាំ វេរាកម្មជិតដោយដាន
នរកប្រេតតិរច្ឆាន ខានឃាត់ខាំងបាំងមគ្គផល ។
78. គួរខំសាងសីលទាន យកនិព្វានជាត្រើយផ្តល់
យូរឆាប់គង់តែដល់ កុសលជួយចាកសង្សារ ។
79. កូនចៅវេរិះគិត មើលគំនិតចិត្តដូនតា
ប្រព្រឹត្តខុសសាសនា គេចកិរិយាកុំធ្វើត្រាប់ ។
80. មើលចាស់ណាត្រឹមត្រូវ ចុះក្នុងផ្លូវគន្លងច្បាប់
ចាស់ស្តីគប្បីស្តាប់ ប្រិតប្រៀងប្រាប់ឱ្យប្រុងចាំ ។
81. គោរពគុណទាំបី សូត្របាលីតាមចំណាំ
រក្សាអង្គសីលប្រាំ កម្មវេរាតាមមិនទាន់ ។
82. សាសនានៅវែងឆ្ងាយ កន្លងឋ្លាយជាងពីរពាន់
សព្វថ្ងៃលៃគ្មេរគ្មាន់ មិនទាន់គ្រប់ជាប្រាំរយ ។
83. ឥឡូវចិត្តប្រាំបី នៅម្តែមួយខាងក្រោយ
កូនចៅកុំបណ្តោយ ឱ្យលិចលង់ក្នុងសសង្សារ ។
84. មានពាក្យចាស់ដំណាល ថាកណ្តាលព្រះសាសនា
ទំនាយក្បួនតម្រា ថានឹងរៀវហើយរីកវិញ ។
85. ហេតុនេះអស់កូនចៅ ទោះល្ងង់ខ្លៅយ៉ាងណាមិញ
ខំឧស្សាហ៍ទន្ទេញ បំពេញពាក្យពុទ្ធទំនាយ ។
86. តំណពីថ្ងៃនេះ រៀនតំរិះកុំភាយមាយ
កូនណាមិនស្វាធ្យាយ មិនរលាយរលត់ទុក្ខ ។



www.elibraryofcambodia.org

87. ដល់សាសនាគ្រប់គ្រាន់ ជួបប្រាំពាន់ទៅខាងមុខ
ទំនាយរាយទំនុក ជាឪពុកម្តាយស្អប់កូន ។
88. ជាកើតអន្តរកប្ប គុំសម្លាប់គ្នាបងប្អូន
មិនដឹងតាដឹងដូន សូន្យសីលទានមិនមានសល់ ។
89. គួរគិតកុំសាងកម្ម កាន់សីលប្រាំចាំដំកល់
ខំសាងមគ្គសាងផល នឹងបានដល់ឋានសាន្តសុខ ។
90. នឹងរួចពីកាប់ចាក់ មិនបានធ្លាក់ទៅនរក
ព្រះសិអារ្យត្រាស់ខាងមុខ រសាយទុក្ខសោករាល់ថ្ងៃ ។
91. នេះហៅច្បាប់បណ្តាំ ជាពាក្យប្រាំៗមួយផ្ទួនៗ
បទព្រហ្មគ្រប់ឃ្លាប្អូន ជូនថែងចប់ម្ល៉េះហើយហោង ។

យើងខ្ញុំ ដានីញ៉ែល ឡៅ-ឡូពេស៍ នឹង ពីទ័រ ឡៅ-ឡូពេស៍

**Daniel and Peter Lau-Lopez**

ជាអ្នកស្ម័គ្រចិត្តឧបត្ថម្ភការផ្សាយសៀវភៅ

**បណ្តាំក្រមង៉ុយ**

ជា eBook បង្កើតឡើងដោយ មូលនិធិខ្មែរសំរាប់ការសិក្សា ជាការរំលឹកគុណដល់
លោក ជីតា ញឹម សយ នឹង អ្នកម្តាយ សូភី ញឹម ឡៅ-ឡូពេស៍
ព្រមទាំង លោកឪពុក វិចទ័រ ឡៅ-ឡូពេស៍

វាយបញ្ចូល ជា e book ដោយ សៀង ស្រីណុច

កញ្ញា ២០១២

www.elibraryofcambodia.org